ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

PHNOM PENH WATER SUPPLY AUTHORITY

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
លេខៈ ០០៩៣.គ.ជ.ណ

ថ្ងៃ......................ខែ..........................ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី..១០....ខែ..មករា..ឆ្នាំ២០២២

**សូមជម្រាបជូន**
**-លោកប្រធានក្រុមហ៊ុន បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក**
**-លោកស្រីប្រធានក្រុមហ៊ុន ខេ ភី អឹម ជី ខេមបូឌា**

**កម្មវត្ថុ**: ប្រកាសលុបចោលការដេញថ្លៃស្តីពីការផ្តល់សេវាសវនកម្ម និងត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ការិយបរិច្ឆេទ២០២២ ជូនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

**យោង**: -កំណត់ហេតុបើកឯកសារដេញថ្លៃ(លើកទី២) ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោក-លោកស្រីប្រធានក្រុមហ៊ុនមេត្តាជ្រាបថា៖ យោងតាមការវាយតម្លៃលើឯកសារដេញថ្លៃរបស់ក្រុមហ៊ុនស្តីពីការផ្តល់សេវាសវនកម្ម និងត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ការិយបរិច្ឆេទ២០២២ ជូនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ឃើញថា ប្រាក់កក់ធានាការដេញថ្លៃរបស់ក្រុមហ៊ុន បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក មានសុពលភាពខ្លីជាងការកំណត់របស់សៀវភៅបន្ទុកនៃឯកសារដេញថ្លៃ មិនអាចទទួលយកបាន រីឯតម្លៃដេញថ្លៃដែលបានដាក់ដោយក្រុមហ៊ុន ខេ ភី អឹម ជី ខេមបូឌា ខ្ពស់ជាងឥណទានជានាចំណាយច្រើន ដូចនេះរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញសូមប្រកាសលុបចោលការដេញថ្លៃនេះ។

ក្រុមហ៊ុនអាចដាក់ពាក្យដកប្រាក់កក់ធានាការដេញថ្លៃពីរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅរាល់ម៉ោងធ្វើការចាប់ពីថ្ងៃប្រកាសនេះតទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក-លោកស្រីប្រធានក្រុមហ៊ុន មេត្តាជ្រាប និងអធ្យាស្រ័យ។

សូម លោក-លោកស្រីប្រធានក្រុមហ៊ុន ទទួលនូវការគោរពរាប់អានពីខ្ញុំ។

**ជ. គណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធានទី១**

**ម៉ា ណូវ៉ាទីន**

ចម្លងជូន៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-គ្រប់សមាជិកគណៈកម្មាធិការលទ្ធកម្ម
-អង្គភាពលទ្ធកម្ម
"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ